ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :......៤០......សសរ.

# សេចក្ដីសម្រេច

## ស្ដីពីការបង្កើតគណៈកម្មការស្រាវជ្រាវបាតុភាពផ្ទុះគ្រាប់បែក នៅសណ្ឋាគារ ហុង កុង និងសណ្ឋាគារ ម៉ាន អ៊ី ( ហៅ ពេញចិត្ត )

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវបាតុភាពករណីដាក់អោយផ្ទុះគ្រាប់បែកនៅសណ្ឋាគារ ហុង កុង និងសណ្ឋាគារ ម៉ាន អ៊ី ( ហៅ ពេញចិត្ត ) កាលពីថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០១ ដូចមានសមាសភាព រាយនាមខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្ដម ហុក ឡងឌី | អគ្គនាយកនគរបាលជាតិ | ជាប្រធាន |
| ២- ឯកឧត្ដម សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ជាអនុប្រធាន |
| ៣- ឯកឧត្ដម អ៊ី ជន | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៤- ឯកឧត្ដម មល់ រឿប | ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី | ជាសមាជិក |
| ៥- ឯកឧត្ដម យូ ស៊ិនឡុង | ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី | ជាសមាជិក |
| ៦- ឯកឧត្ដម នេត សាវឿន | ប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ | ជាសមាជិក |
| ៧- លោកឧត្ដមសេនីយ៍ត្រី សុខ ផល | ប្រធាននាយកដ្ឋានពត៌មានទូទៅ | ជាសមាជិក |
| ៨- លោកឧត្ដមសេនីយ៍ត្រី វង្ស ពិសេន | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | ជាសមាជិក |
| ៩- លោកឧត្ដមសេនីយ៍ត្រី សួន ឈាងលី | ស្នងការនគរបាលរាជធានីភ្នំពេញ | ជាសមាជិក |

www.pheakdeylaw.com

**ប្រការ ២:** គណៈកម្មការនេះមានភារកិច្ចដូចតទៅ ÷

- ស្រាវជ្រាវគ្រប់មូលហេតុអោយបានហ្មត់ចត់ ដែលកើតមានឡើងចំពោះករណីការដាក់អោយផ្ទុះគ្រាប់បែក នៅសណ្ឋាគារ ហុង កុង និង សណ្ឋាគារ ម៉ាន អ៊ី ( ហៅ ពេញចិត្ត ) កាលពីថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០១ កន្លងមក ។
- គណៈកម្មការនេះមានសិទ្ធិកោះអញ្ជើញគ្រប់សមាសភាពដែលពាក់ព័ន្ធមកបំភ្លឺ ។
- រាយការណ៍ពីលទ្ធផលជូននាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី ស ខេង ដើម្បីពិនិត្យ និងសំរេច ។
- គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋាននគរបាលជាតិ ។
- សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ។

**ប្រការ ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធករណីខាងលើ និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០១*

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ- កាលប្បវត្តិ*

www.pheakdeylaw.com